# របៀបដែល ស៊ីដេ មាន ភាពក្លាហាន

**ដោយ លូស៊ី ស្ទីវ៉ែនសុន អ៊ីវែល**
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

ស៊ីដេ បានដកដង្ហើមធំ ហើយបានដើរចូលទៅក្នុងថ្នាក់រៀនថ្មីរបស់នាង ។ វាគឺជាថ្ងៃដំបូងរបស់នាងនៅថ្នាក់ទីបួន ។

ឆ្នាំមុន ស៊ីដេ រៀននៅថ្នាក់ទីពីរ ។ នាងរៀនពូកែយ៉ាងខ្លាំង រហូតដល់សាលារបស់នាងឲ្យនាងឆ្លោះថ្នាក់ទីបី ។ ស៊ីដេ រំភើបចិត្តនឹងធ្វើលំហាត់គណិតវិទ្យាពិបាក។ ហើយអានសៀវភៅកាន់តែច្រើនជាងមុននៅថ្នាក់ទីបួន ។ ប៉ុន្តែ នាងមិនរីករាយនោះទេ ដែលនាងត្រូវចាកចេញពីមិត្តចាស់ៗរបស់នាង ។

នៅពេលនាងក្រឡេកមើលជុំវិញថ្នាក់រៀន ស៊ីដេ មានអារម្មណ៍ថាខ្លួនឯងតូច ។ មិត្តរួមថ្នាក់ថ្មីៗរបស់នាងទាំងអស់មើលទៅធំជាង និងខ្ពស់ជាងនាង ។ ចុះបើនាងចូលមិនចុះចំណោមគេនោះ ?



*ស៊ីដេ មានអារម្មណ៍ខ្លាចយ៉ាងខ្លាំងក្នុងការនិយាយចូលមិត្តរួមថ្នាក់របស់នាង ។*

នាងបានចាប់តុមួយ ហើយអង្គុយចុះ ។ កុមារីខ្ពស់ម្នាក់បានអង្គុយក្បែរនាង ។ ស៊ីដេ បាននិយាយថា « សួស្ដី » ។

កុមារីនោះបានសួរថា « តើឯងធ្វើអ្វីនៅទីនេះ ? ខ្ញុំគិតថា ឯងត្រូវរៀននៅថ្នាក់ទីបីបានត្រូវ » ។

ស៊ីដេ ឆ្លើយទាំងភ័យថា « សាលាឲ្យខ្ញុំឆ្លោះមួយថ្នាក់ » ។

ក្មេងស្រីនោះធ្វើមុខពេបជ្រាយដាក់ ។ « ខ្ញុំមិនខ្វល់ថាឯងពូកែខ្លាំងប៉ុណ្ណានោះទេ ។ ឯងនៅតែជាកូនង៉ែតដដែល » ។

ស៊ីដេ មានអារម្មណ៍មិនល្អសោះក្នុងចិត្ត ។ ពេញមួយសប្ដាហ៍ នាងខ្លាចមិនហ៊ាននិយាយចូលមិត្តរួមថ្នាក់របស់នាងណាម្នាក់ឡើយ ។ រាល់ពេលដែលនាងឮនរណាម្នាក់សើច ឬនិយាយខ្សឹប។ នាងចង់ចិញ្ចើម ។ ពួកគេប្រហែលជានិយាយរឿងមិនល្អអំពីនាងហើយ ។

ចំពេលដែលនាងគិតថា អ្វីៗកាន់តែអាក្រក់ទៅ។ នោះស៊ីដេ បានលទ្ធផលលំហាត់គណិតវិទ្យាមកវិញ ។ នាងចង់តែយំទេ នៅពេលនាងមើលទៅពិន្ទុរបស់នាងនោះ ។ គណិតវិទ្យាគឺជាមុខវិជ្ជាដែលនាងចូលចិត្តបំផុត ។ នាងមិនដែលទទួលបានពិន្ទុអន់យ៉ាងនេះទេពីមុនមក ។

ពេលនាងទៅដល់ផ្ទះ ស៊ីដេ មិនអាចទប់ទឹកភ្នែករបស់នាងបានទេ ។ នាងបានប្រាប់ឪពុកម្ដាយរបស់នាងថា « កូនអត់មានមិត្តភក្ដិទេ ។ កូនមិនសមរៀននៅថ្នាក់ទីបួនទេ ។ កូនមិនសូវឆ្លាតនោះទេ » ។

ម្ដាយរបស់ ស៊ីដេ បាននិយាយថា « ម៉ាក់សោកស្ដាយដែលវាពិបាកខ្លាំង ។ ប៉ុន្តែកូន *គឺ* ពូកែណាស់ ។ ហើយកូននៅតែបន្តរៀនសូត្រ » ។

ស៊ីដេ ជូតទឹកភ្នែករបស់នាង ។ « ខ្ញុំចង់ទៅរៀននៅថ្នាក់ទីបីវិញ » ។

ប៉ានាងបាននៅស្ងៀមមួយសន្ទុះ ។ រួចគាត់បានសួរថា « តើកូនចង់បានពរជ័យបព្វជិតភាពដែរឬទេ ? »

ស៊ីដេ បានងក់ក្បាល ។ ប្រហែលពរជ័យពីប៉ានាង នឹងជួយនាងឲ្យមានអារម្មណ៍ប្រសើរឡើងវិញ ។

ស៊ីដេ អង្គុយនៅលើកៅអី ហើយប៉ាដាក់ដៃគាត់នៅលើក្បាលនាង ។

ប៉ាបានពោលថា « ប៉ាប្រសិទ្ធពរដល់កូន ដើម្បីកុំឲ្យកូនភ័យខ្លាច ។ ហើយប៉ាប្រសិទ្ធពរកូនឲ្យស្រឡាញ់មិត្តរួមថ្នាក់ថ្មីៗរបស់កូន ។ នៅពេលពួកគេស្គាល់កូន នោះពួកគេនឹងស្រឡាញ់កូនដែរ » ។



អារម្មណ៍ស្ងប់បានចូលក្នុងចិត្តរបស់ស៊ីដេ ។ នាងមានអារម្មណ៍ថា ពាក្យពេចន៍របស់ប៉ានាងគឺជាអ្វីដែលព្រះវរបិតាសួគ៌ចង់ឲ្យនាងស្ដាប់ឮ ។

បន្ទាប់ពីការប្រសិទ្ធពរ ម៉ាក់បានជួយ ស៊ីដេ ឲ្យធ្វើលំហាត់គណិតវិទ្យារបស់នាង ។ ភ្លាមៗនោះ ស៊ីដេ មានអារម្មណ៍ធូរចិត្តបន្តិច ។

នៅថ្ងៃបន្ទាប់នៅសាលារៀន ស៊ីដេ ចងចាំដល់ពរជ័យរបស់នាង ហើយបានព្យាយាមដើម្បីមានភាពក្លាហាន ។ នាងបានញញឹមដាក់មិត្តរួមថ្នាក់របស់នាង ។ នៅពេលនាងបង្ហាញសេចក្ដីស្រឡាញ់ នោះនាងមិនសូវមានអារម្មណ៍ខ្លាចពួកគេនោះទេ ! ពួកគេមួយចំនួនថែមទាំងមានចិត្តល្អខ្លាំងទៀតផង ។ នាងបានខិតខំរៀនសូត្រយ៉ាងខ្លាំង ហើយមិនយូរប៉ុន្មាន ពិន្ទុរបស់នាងបានល្អឡើងវិញ ។

នៅចុងឆ្នាំសិក្សា ស៊ីដេ បានមានមិត្តភក្ដិជាច្រើន ។ នាងរីករាយដែលព្រះវរបិតាសួគ៌បានជួយនាងឲ្យមានភាពក្លាហាន ។ ហើយនាងមានអំណរគុណ ដែលនាងតែងតែអាចមានពរជ័យនៃអំណាចបព្វជិតភាពដើម្បីជួយដល់នាងជានិច្ច ។ ●

*រឿងនេះបានកើតឡើងនៅក្នុងប្រទេសលីបេរីយ៉ា ។*